**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ :** ៦៤ អនក្រ.បក

# អនុក្រឹត្យ
# ស្តីពី
# ឯកសណ្ឋាន សញ្ញាសម្គាល់ និងសញ្ញាសក្តិ របស់មន្ត្រីអធិការកិច្ចទេសចរណ៍

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួលនិងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤១៦/៣៦៨ ចុះថ្ងៃទី៤ ខែមេសា ឆ្នាំ២០១៦ ស្តីពីការកែសម្រួលនិងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៣/០១២ ចុះថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០១៣ ស្តីពីវិសោធនកម្មមាត្រា២៨នៃច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ០៦/នស/៩៤ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៥ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងទេសចរណ៍
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០៩/០០៧ ចុះថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០០៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីទេសចរណ៍
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១០១៤/១១៧៥ ចុះថ្ងៃទី០២ ខែតុលា ឆ្នាំ២០១៤ ស្តីពីគោលការណ៍រួមនៃការរៀបចំមុខងារសាធារណៈរបស់រដ្ឋ/



www.pheakdeylaw.com

- បានឃើញអនុក្រឹត្យលេខ១៩៩ អនក្រ.បក ចុះថ្ងៃទី២៦ ខែកញ្ញា ឆ្នាំ២០១៦ ស្តីពីឯកសណ្ឋាន សញ្ញាសម្គាល់ និងសញ្ញាសក្តិរបស់មន្ត្រីអធិការកិច្ចទេសចរណ៍
- បានឃើញអនុក្រឹត្យលេខ២៥៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០១៦ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងទេសចរណ៍
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងទេសចរណ៍

# សម្រេច

## ជំពូកទី១

## បទប្បញ្ញត្តិទូទៅ

**មាត្រា១.-**

អនុក្រឹត្យនេះកំណត់ពីឯកសណ្ឋាន សញ្ញាសម្គាល់ និងសញ្ញាសក្តិរបស់មន្ត្រីអធិការកិច្ចទេសចរណ៍ សម្រាប់ប្រើដើម្បីបំពេញការងារ ចុះអនុវត្តច្បាប់ស្តីពីទេសចរណ៍និងលិខិតបទដ្ឋានគតិយុត្តនានាពាក់ព័ន្ធនឹងវិស័យទេសចរណ៍ក្នុងព្រះរាជាណាចក្រកម្ពុជា។

## ជំពូកទី២

## ឯកសណ្ឋាន

**មាត្រា២.-**

ឯកសណ្ឋានរបស់មន្ត្រីអធិការកិច្ចទេសចរណ៍ត្រូវបានកំណត់ដូចខាងក្រោម៖

**ក- បុរស**

**១- អាវ** មាន៣(បី)ប្រភេទ៖

- អាវធំរ៉ាំរឹងដៃវែងសម្រាប់ពិធីការ
- អាវសាហារីយែនដៃខ្លីសម្រាប់ការងារអធិការកិច្ច
- អាវសឺមីដៃវែងសម្រាប់ពាក់ក្នុងអាវធំ

**១.១- អាវធំរ៉ាំរឹងដៃវែងសម្រាប់ពិធីការ មាន២(ពីរ)ថ្នាក់៖**

**១.១.១- ថ្នាក់អគ្គាធិការ អគ្គាធិការរង អធិការ ប្រធានការិយាល័យថ្នាក់កណ្តាល ប្រធាន និងអនុប្រធានមន្ទីរទេសចរណ៍រាជធានី ខេត្ត**

អាវធំដៃវែងកាត់រាងរ៉ាំរឹ ផលិតពីសាច់ក្រណាត់ពណ៌ខៀវចាស់សម្រាប់ពាក់ក្រៅខោ មានកបើកពីរសន្លឹកមានប៉ូលស្មានៅសងខាងភ្ជាប់ដោយឡេវមានពណ៌ដូចពណ៌អាវ។ នៅផ្នែកខាងមុខនៃអាវ មានដាក់ឡេវរូបព្រះសង្ការពណ៌មាសចំនួន៥(ប្រាំ)គ្រាប់ មានហោប៉ៅចំនួន៤(បួន) ហោប៉ៅពីរខាងលើដេរជាលក្ខណៈប៉ះមានពីរផ្នត់ចំកណ្តាល និងមានគម្របរាងស្លឹកពោធិ៍ និងហោប៉ៅពីរខាងក្រោមដេរជាលក្ខណៈចោះ និងមានគម្របរាងចតុកោណកែងទាលចុងសងខាង។ នៅផ្នែកខាងខ្នងអាវ មានដេរថ្នេរពុះចំកណ្តាលខ្នងកាត់ស្រុងវែងជើងត្រង់ មានឆែកខ្នងផ្នែកខាងក្រោយ។ ផ្នែកដៃអាវកាត់រាងដៃបំពង់ នៅចុងដៃអាវនីមួយៗទុកប្រវែង៧(ប្រាំពីរ)សង្ទីម៉ែត្រ មានដេរខ្សែវេញពណ៌មាសព័ទ្ធជុំវិញ ហើយមានដាក់ភ្ជាប់ឡេវបញ្ចោតរូបព្រះសង្ការ



www.pheakdeylaw.com

ពណ៌មាសចំនួន៤(បួន) គ្រាប់នៅចន្លោះខ្សែវេញ និងចុងដៃអាវទាំងពីរ (រូបភាពទី១ ឧបសម្ព័ន្ធទី១)។ ឯកសណ្ឋានប្រភេទនេះ ត្រូវបានប្រើប្រាស់សម្រាប់ពិធីបុណ្យជាតិ សន្និបាត សវនាការ និងករណីតម្រូវក្នុងពិធីនីមួយៗដោយភ្ជាប់ជាមួយនូវគ្រឿងឥស្សរិយយស (បើមាន)។

**១.១.២- ថ្នាក់អនុប្រធានការិយាល័យថ្នាក់កណ្តាល ប្រធាន អនុប្រធានការិយាល័យនៃមន្ទីរទេសចរណ៍រាជធានី ខេត្ត និងមន្ត្រីអធិការកិច្ច**

អាវធំរ៉ាវីដវែង មានគំរូដូចអាវធំរ៉ាវីថ្នាក់អគ្គាធិការ អគ្គាធិការរង អធិការ ប្រធានការិយាល័យថ្នាក់កណ្តាល ប្រធាន និងអនុប្រធានមន្ទីរទេសចរណ៍រាជធានី ខេត្ត ដែរ ប៉ុន្តែខុសត្រង់ឡេវអាវព្រះសង្ការ និងនៅចុងដៃអាវនីមួយៗមានដាក់ខ្សែវេញពណ៌ទឹកប្រាក់ (រូបភាពទី២ ឧបសម្ព័ន្ធទី១)។

**១.២- អាវសាហារីយែនដៃខ្លីសម្រាប់ការងារអធិការកិច្ចមាន២ (ពីរ)ថ្នាក់**

**១.២.១- ថ្នាក់អគ្គាធិការ អគ្គាធិការរង អធិការ ប្រធានការិយាល័យថ្នាក់កណ្តាល ប្រធាន និងអនុប្រធានមន្ទីរទេសចរណ៍រាជធានី ខេត្ត**

អាវសាហារីយែនដៃខ្លី ផលិតពីសាច់ក្រណាត់ពណ៌សសម្រាប់ពាក់ក្រៅខោ មានកបើកពីរសន្លឹក មានដាក់ឡេវរូបព្រះសង្ការពណ៌មាសចំនួន៥(ប្រាំ)គ្រាប់ មានប៉ូលស្មានៅសងខាងភ្ជាប់ដោយឡេវពណ៌ដូចពណ៌អាវ មានហោប៉ៅចំនួន៤(បួន) ហោប៉ៅពីរខាងលើដេរជាលក្ខណៈប៉ះមានពីរផ្នត់ចំកណ្តាល មានគម្របរាងចតុកោណកែងបិតចុងសងខាង ហោប៉ៅពីរខាងក្រោមដេរដូច ហោប៉ៅពីរខាងលើដែរ ប៉ុន្តែខុសត្រង់មានទំហំធំជាង។ នៅផ្នែកខាងខ្នងនៃអាវដេរថ្នេរពុះចំកណ្តាលខ្នងកាត់ស្រុងវែង ជើងត្រង់មានផែកខ្នងផ្នែកខាងក្រោម (រូបភាពទី៣ ឧបសម្ព័ន្ធទី១)។

**១.២.២- ថ្នាក់អនុប្រធានការិយាល័យថ្នាក់កណ្តាល ប្រធាន អនុប្រធានការិយាល័យមន្ទីរទេសចរណ៍រាជធានី ខេត្ត និងមន្ត្រីអធិការកិច្ច**

អាវសាហារីយែនដៃខ្លី មានគំរូដូចអាវថ្នាក់អគ្គាធិការ អគ្គាធិការរង អធិការ ប្រធានការិយាល័យថ្នាក់កណ្តាល ប្រធាន និងអនុប្រធានមន្ទីរទេសចរណ៍រាជធានី ខេត្ត ដែរ ប៉ុន្តែខុសត្រង់ឡេវអាវព្រះសង្ការពណ៌ទឹកប្រាក់ (រូបភាពទី៤ ឧបសម្ព័ន្ធទី១)។

**១.៣- អាវសឺមីដៃវែងសម្រាប់ពាក់ក្នុងអាវធំ**

អាវសឺមីដៃវែង ផលិតពីសាច់ក្រណាត់ពណ៌ផ្ទៃមេឃកឌុប ឡេវជ័រពណ៌សដេរថ្នេរបង្កប់មានហោប៉ៅមួយដេរជាលក្ខណៈប៉ះគ្មានគម្របកាត់ស្រុងវែងជើងត្រង់(រូបភាពទី៥ ឧបសម្ព័ន្ធទី១)។

**២- ខោជើងវែង**

ខោជើងវែង ផលិតពីសាច់ក្រណាត់ពណ៌ខៀវចាស់ចង្កេះត ដេរថ្នេរបង្កប់ជីបក្លីខាងមុខពីរមានហោប៉ៅបួន ហោប៉ៅចំហៀងទាំងសងខាងដេរបញ្ឆិតតាមថ្នេរ ចំហៀងខោ និងហោប៉ៅក្រោយពីរដេរថ្នេរបង្កប់ និងមានឡេវមួយបង្កប់(រូបភាពទី៦ ឧសម្ព័ន្ធទី១)។

**៣- ក្រវ៉ាត់ក**

ក្រវ៉ាត់កមានមួយប្រភេទធ្វើពីក្រណាត់ពណ៌ខៀវចាស់លាត(រូបភាពទី៧ ឧសម្ព័ន្ធទី១)។



www.pheakdeylaw.com

**៤- ស្បែកជើង**

ស្បែកជើងឃ្លុបប្រភេទស្បែក ពណ៌ខ្មៅ មានចងខ្សែ គខ្លី មានកែង និងមានស្រោមជើង ពណ៌ខ្មៅ(រូបភាពទី៨ ឧសម្ព័ន្ធទី១)។

**៥- ខ្សែក្រវាត់**

ខ្សែក្រវាត់ផលិតពីស្បែក ពណ៌ខ្មៅ មានក្បាលពណ៌មាស(រូបភាពទី៩ ឧបសម្ព័ន្ធទី១)។

**៦- មួក**

**មួកកាស្កែតសម្រាប់បុរស មាន៧(ប្រាំពីរ)ថ្នាក់**

**៦.១- ថ្នាក់អគ្គាធិការ**

មួកកាស្កែត ផលិតពីសាច់ក្រណាត់ពណ៌ខៀវចាស់ ខាងលើនៃផ្នែកខាងមុខមួក មានភ្ជាប់ព្រះសង្ហារពណ៌មាសបញ្ឈរមានកម្ពស់៧,៨សង្ទីម៉ែត្រ និងទទឹង៦,៨សង្ទីម៉ែត្រ។ ក្រោមព្រះសង្ហារមានកណ្ដាប់វ័ណ្ឌ ផលិតពីសាច់ក្រណាត់ពណ៌ផ្ទៃមេឃព័ទ្ធជុំវិញ។ ខាងក្រោមកណ្ដាប់វ័ណ្ឌប៉ែកខាងមុខមានក្បាំងពណ៌ខ្មៅ។ នៅលើកណ្ដាប់វ័ណ្ឌផ្នែកខាងមុខប៉ែកខាងលើមានប៉ាក់ក្បាច់ភ្ញីទេសពណ៌មាស ហើយចំកណ្ដាលមានប៉ាក់រូបសញ្ញាសម្គាល់ញញួរ និងគូនសោពណ៌មាស។ នៅលើកណ្ដាប់វ័ណ្ឌផ្នែកខាងមុខប៉ែកខាងក្រោម មានកម្រងខ្សែសយក្រងពណ៌មាសចំនួន ៤សរសៃ ភ្ជាប់ដោយឡេវរូបព្រះសង្ហារពណ៌មាសនៅចុងខ្សែទាំងសងខាង។ នៅលើក្បាំងមួកមានប៉ាក់ក្បាច់ភ្ញីទេសពណ៌មាស មានទម្រង់ដូចស្លែងក្របីដល់ជើងមួក(រូបភាពទី១០ ឧបសម្ព័ន្ធទី១)។

**៦.២- ថ្នាក់អគ្គាធិការរង**

មួកកាស្កែតមានទម្រង់ដូចមួករបស់អគ្គាធិការដែរ ប៉ុន្តែខុសគ្នាត្រង់នៅលើកណ្ដាប់វ័ណ្ឌផ្នែកខាងមុខប៉ែកខាងក្រោម មានកម្រងខ្សែសយក្រងពណ៌មាសចំនួន៣សរសៃ ភ្ជាប់ដោយឡេវរូបព្រះសង្ហារពណ៌មាសនៅចុងខ្សែទាំងសងខាង។ នៅលើក្បាំងមួកមានប៉ាក់ក្បាច់ភ្ញីទេសពណ៌មាស មានទម្រង់ដូចស្លែងក្របីដល់ជើងមួក(រូបភាពទី១០ ឧបសម្ព័ន្ធទី១)។

**៦.៣- ថ្នាក់អធិការ**

មួកកាស្កែត ផលិតពីសាច់ក្រណាត់ពណ៌ខៀវចាស់ ខាងលើនៃផ្នែកខាងមុខមួក មានភ្ជាប់ព្រះសង្ហារពណ៌មាសបញ្ឈរមានកម្ពស់៧,៨សង្ទីម៉ែត្រនិងទទឹង៦,៨សង្ទីម៉ែត្រ។ ក្រោមព្រះសង្ហារមានកណ្ដាប់វ័ណ្ឌ ផលិតពីសាច់ក្រណាត់ពណ៌ផ្ទៃមេឃព័ទ្ធជុំវិញ។ ខាងក្រោមកណ្ដាប់វ័ណ្ឌប៉ែកខាងមុខមានក្បាំងពណ៌ខ្មៅ។ នៅលើកណ្ដាប់វ័ណ្ឌផ្នែកខាងមុខប៉ែកខាងក្រោមនៃកណ្ដាប់វ័ណ្ឌមានកម្រងខ្សែសយក្រងពណ៌មាសចំនួន៦សរសៃ ភ្ជាប់ដោយឡេវរូបព្រះសង្ហារពណ៌មាសនៅចុងខ្សែទាំងសងខាង។ នៅលើក្បាំងមួកមានប៉ាក់ក្បាច់ភ្ញីទេសពណ៌មាសមានទម្រង់ដូចស្លែងក្របីដល់ជើងមួក(រូបភាពទី១០ ឧបសម្ព័ន្ធទី១)។

**៦.៤- ថ្នាក់ប្រធានមន្ទីរទេសចរណ៍រាជធានី ខេត្ត**

មួកកាស្កែត ផលិតពីសាច់ក្រណាត់ពណ៌ខៀវចាស់ ខាងលើនៃផ្នែកខាងមុខមួក មានភ្ជាប់ព្រះសង្ហារពណ៌មាសបញ្ឈរមានកម្ពស់៧,៨សង្ទីម៉ែត្រនិងទទឹង៦,៨សង្ទីម៉ែត្រ។ ក្រោមព្រះសង្ហារមានកណ្ដាប់វ័ណ្ឌផលិតពីសាច់ក្រណាត់ពណ៌ផ្ទៃមេឃព័ទ្ធជុំវិញ។ ខាងក្រោមកណ្ដាប់...



www.pheakdeylaw.com

វ័ណ្ឌបែ៉កខាងមុខមានក្បាំងពណ៌ខ្មៅ។ នៅលើកណ្តាប់វ័ណ្ឌផ្នែកខាងមុខប៉ែកខាងក្រោមនៃកណ្តាប់វ័ណ្ឌមានកម្រងខ្សែសយក្រងពណ៌មាសចំនួន៦សរសៃ ភ្ជាប់ដោយឡេវរូបព្រះសង្ការពណ៌មាសនៅចុងខ្សែទាំងសងខាង។ នៅលើក្បាំងមួកមានប៉ាក់ក្បាច់ភ្ញីទេសពណ៌មាស មានទម្រង់ដូចស្នែងក្របី ដោយទុកចន្លោះ៤សង្ទីម៉ែត្រពីជើងមួកទាំងសងខាង (រូបភាពទី១០ ឧបសម្ព័ន្ធទី១)។

**៦.៥- ថ្នាក់ប្រធានការិយាល័យថ្នាក់កណ្តាលនិងអនុប្រធានមន្ទីរទេសចរណ៍រាជធានី ខេត្ត**

មួកកាស្កេត ផលិតពីសាច់ក្រណាត់ពណ៌ខៀវចាស់ ខាងលើនៃផ្នែកខាងមុខមួកមានភ្ជាប់ព្រះសង្ការពណ៌មាសបញ្ឈរមានកម្ពស់៧,៥សង្ទីម៉ែត្រនិងទទឹង៦,៨សង្ទីម៉ែត្រ។ ក្រោមព្រះសង្ការមានកណ្តាប់វ័ណ្ឌផលិតពីសាច់ក្រណាត់ពណ៌ផ្ទៃមេឃព័ទ្ធជុំវិញ។ ខាងក្រោមកណ្តាប់វ័ណ្ឌប៉ែកខាងមុខមានក្បាំងពណ៌ខ្មៅ។ នៅលើកណ្តាប់វ័ណ្ឌផ្នែកខាងមុខប៉ែកខាងក្រោមនៃកណ្តាប់វ័ណ្ឌមានកម្រងខ្សែសយក្រងពណ៌មាសចំនួន៣សរសៃ ភ្ជាប់ដោយឡេវរូបព្រះសង្ការពណ៌មាសនៅចុងខ្សែទាំងសងខាង។ នៅលើក្បាំងមួកមានប៉ាក់ក្បាច់ភ្ញីទេសពណ៌មាស មានទម្រង់ដូចស្នែងក្របីដោយទុកចន្លោះ៤សង្ទីម៉ែត្រពីជើងមួកទាំងសងខាង(រូបភាពទី១០ ឧបសម្ព័ន្ធទី១)។

**៦.៦- ថ្នាក់អនុប្រធានការិយាល័យថ្នាក់កណ្តាលនិងប្រធានការិយាល័យមន្ទីរទេសចរណ៍រាជធានី ខេត្ត**

មួកកាស្កេត មានទម្រង់ដូចមួករបស់ប្រធានការិយាល័យថ្នាក់កណ្តាល និងអនុប្រធានមន្ទីរទេសចរណ៍រាជធានី ខេត្តដែរ ប៉ុន្តែខុសគ្នាត្រង់កម្រងខ្សែសយ ឡេវព្រះសង្ការ និងប៉ាក់ក្បាច់ភ្ញីទេសមានពណ៌ទឹកប្រាក់(រូបភាពទី១០ ឧបសម្ព័ន្ធទី១)។

**៦.៧- ថ្នាក់មន្ត្រីនិងអនុប្រធានការិយាល័យមន្ទីរទេសចរណ៍រាជធានី ខេត្ត**

មួកកាស្កេត មានទម្រង់ដូចមួករបស់អនុប្រធានការិយាល័យថ្នាក់កណ្តាល និងប្រធានការិយាល័យមន្ទីរទេសចរណ៍រាជធានី ខេត្តដែរ ប៉ុន្តែខុសគ្នាត្រង់នៅលើជាយក្បាំងមួក មានតែខ្សែសំប៉ែតទំហំ៥មីលីម៉ែត្រ ពណ៌ទឹកប្រាក់ព័ទ្ធវង់ដល់ជើងមួក(រូបភាពទី១០ ឧបសម្ព័ន្ធ ទី១)។

**ខ- ស្ត្រី**

**១- អាវមាន៣(បី)ប្រភេទ៖**

- អាវធំរ៉ាំរីដៃវែង(សម្រាប់ពិធីការ)មានរាងដូចអាវបុរសដែរ តែខុសត្រង់មានជីបរាង (រូបភាពទី១និងទី២ឧបសម្ព័ន្ធទី១)។
- អាវសាហារីយែនដៃខ្លី(សម្រាប់ការងាររដ្ឋបាលកិច្ច)មានរាងដូចអាវបុរសដែរ តែខុសត្រង់មានជីបរាង(រូបភាពទី៣និងទី៤ឧបសម្ព័ន្ធទី១)។
- អាវសឺមីដៃវែង (សម្រាប់ពាក់ក្នុងអាវធំ) មានរាងដូចអាវបុរសដែរ តែខុសត្រង់មានជីបរាង (រូបភាពទី៥ឧបសម្ព័ន្ធទី១)។

**២- សំពត់**

សំពត់ ផលិតពីសាច់ក្រណាត់ពណ៌ខៀវចាស់(រូបភាពទី១១ ឧបសម្ព័ន្ធទី១)។

**៣- ក្រវ៉ាត់ក**

ក្រវ៉ាត់កមានមួយប្រភេទពណ៌ខៀវចាស់លាតដូចបុរស (រូបភាពទី៧ ឧបសម្ព័ន្ធទី១)។



www.pheakdeylaw.com

៤- **ស្បែកជើង**

ស្បែកជើងឃ្លុបប្រភេទស្បែក ពណ៌ខ្មៅ គ្មានចងខ្សែ កខ្លី ឃ្លុបមុខក្រោយមានកែងទាប (រូបភាពទី១២ ឧបសម្ព័ន្ធទី១)។

៥- **មួកស្ត្រី មាន៧(ប្រាំពីរ)ថ្នាក់**

មួកស្ត្រី មានលក្ខណៈដូចមួកកាស្កេត ទៅតាមកម្រិតថ្នាក់នីមួយៗរបស់បុរសដែរ ប៉ុន្តែខុសត្រង់ ហាមជើងមួក ដេរដោយសាច់ក្រណាត់ជុំវិញបត់ភ្ជើយជើងមួកផ្នែកខាងក្រោយ (រូបភាពទី១៣ ឧបសម្ព័ន្ធទី១)។

## ជំពូកទី៣
## សញ្ញាសម្គាល់

**មាត្រា៣ .-**

សញ្ញាសម្គាល់របស់មន្ត្រីអធិការកិច្ចទេសចរណ៍ ត្រូវបានកំណត់ដូចខាងក្រោម៖

១- ស្លាកសញ្ញាសម្គាល់រូបសញ្ញាក្រសួងទេសចរណ៍ ត្រូវប៉ាក់ពីលើសាច់ក្រណាត់រាងមូលដែលមានទំហំអង្កត់ផ្ចិត៧សង្ទីម៉ែត្រ ដោយដេរភ្ជាប់ពីលើដើមដៃអាវខាងស្តាំ (រូបភាពទី១៤ ឧសម្ព័ន្ធទី២)។

២- ស្លាកសញ្ញាមន្ត្រីនគរបាលយុត្តិធម៌ក្រសួងទេសចរណ៍ មានរូបសញ្ញាក្រសួងទេសចរណ៍ធ្វើពីលោហធាតុរាងមូលប៉ោងទំហំអង្កត់ផ្ចិត៥សង្ទីម៉ែត្រ ពណ៌មាសផុសឡើង ភ្ជាប់លើបន្ទះស្បែកពណ៌ខៀវចាស់សម្រាប់ព្យួរនៅហោប៉ៅអាវលើខាងស្តាំ។ នៅផ្ទៃរង្វង់ខាងលើមានសរសេរអក្សរខ្មែរពណ៌មាស "**អធិការកិច្ចទេសចរណ៍**" នៅផ្ទៃរង្វង់ខាងក្រោមមានសរសេរអក្សរខ្មែរពណ៌មាស "**នគរបាលយុត្តិធម៌**" នៅចុងអង្កត់ផ្ចិតនៃពាក្យទាំងពីរមានលម្អដោយផ្កាចន្ទន៍។ ស្លាកសញ្ញានេះត្រូវបានប្រើប្រាស់សម្រាប់មន្ត្រីអធិការកិច្ចទេសចរណ៍ ដែលបានបំពេញនីតិសម្បទាជានគរបាលយុត្តិធម៌ (រូបភាពទី១៥ ឧបសម្ព័ន្ធទី២)។

៣- ស្លាកឈ្មោះនិងអត្តលេខត្រូវកំណត់យកស្លាករាងចតុកោណកែងមានបណ្តោយ៩,៦សង្ទីម៉ែត្រ និងទទឹង២,៥សង្ទីម៉ែត្រ ធ្វើពីលោហធាតុបិទជ័រវឹងពីខាងលើផ្ទៃខាងក្នុងមានពណ៌ខៀវចាស់ព័ទ្ធដោយខ្សែបន្ទាត់ស្តើងពណ៌មាស។ ផ្នែកខាងមុខ មួយភាគបួននៃស្លាកមានសរសេរអត្តលេខពណ៌មាស និងបីភាគបួន មានសរសេរឈ្មោះជាអក្សរខ្មែរនិងអក្សរឡាតាំងពណ៌មាសនៅខាងក្រោមសម្រាប់ពាក់ពីលើហោប៉ៅអាវលើខាងស្តាំ (រូបភាពទី១៦ ឧបសម្ព័ន្ធទី២)។

៤- ស្លាកសញ្ញាសម្គាល់សម្រាប់ពាក់នៅចុងកអាវទាំងសងខាង មានទំហំទទឹង៣សង្ទីម៉ែត្រនិងកម្ពស់៣,៥សង្ទីម៉ែត្រ មានរូបសញ្ញាជើងពានទ្រលិខិតបទដ្ឋានគតិយុត្ត ដោយមានរូបកូនសោនិងញញួរខ្វែងពីលើ។ ស្លាកសញ្ញាពណ៌មាសត្រូវបានប្រើប្រាស់ដោយថ្នាក់អគ្គាធិការ អគ្គាធិការរងអធិការ ប្រធានការិយាល័យ ប្រធាន អនុប្រធានមន្ទីរទេសចរណ៍រាជធានី ខេត្ត និងពណ៌ទឹកប្រាក់ ត្រូវបានប្រើប្រាស់ដោយថ្នាក់អនុប្រធានការិយាល័យ ប្រធាន អនុប្រធានការិយាល័យមន្ទីរទេសចរណ៍រាជធានី ខេត្តរហូតដល់មន្ត្រីអធិការកិច្ច(រូបភាពទី១៧ ឧបសម្ព័ន្ធទី២)។

៥- ស្លាកបណ្ណំគ្រឿងឥស្សរិយយស ត្រូវរៀបតាមលំដាប់លំដោយ ដែលសាមីខ្លួនម្នាក់ៗបានទទួលបណ្ណំគ្រឿងឥស្សរិយយសត្រូវពាក់ពីលើគម្របហោប៉ៅអាវខាងឆ្វេង២សង្ទីម៉ែត្រសម្រាប់ចូលរួមពិធីផ្លូវការ(បើមាន)។/.



www.pheakdeylaw.com

## ជំពូកទី៤
## សញ្ញាសក្តិ

**មាត្រា៤ .-**

សញ្ញាសក្តិសម្រាប់ពាក់លើស្មាអាវសងខាង មានចំនួន៧(ប្រាំពីរ)ថ្នាក់ ត្រូវបានកំណត់ដូចខាងក្រោម៖

**១- ថ្នាក់អគ្គាធិការ**

សក្តិស្មាមានផ្ទៃកម្ពីពណ៌ខៀវចាស់ ព័ទ្ធជុំវិញដោយក្បាច់ភ្ញីទេសអមដោយខ្សែវេញពណ៌មាសពីរសរសៃ។ នៅផ្នែកខាងលើមានឡេវរូបព្រះសង្ហារពណ៌មាសមួយនៅជិតកំពូលមុំ។ នៅចំកណ្តាលមានប៉ាក់រូបសញ្ញាសម្គាល់មន្ត្រីនគរបាលយុត្តិធម៌នៃក្រសួងទេសចរណ៍ពណ៌មាស។ ផ្នែកខាងក្រោមមានខ្សែវេញពណ៌មាសប្រាំខ្សែនិងមានក្បាច់ផ្កាចន្ទន៍និងក្បាច់ភ្ញីទេសពណ៌មាស ព្រមទាំងមានប៉ាក់អក្សរកាត់ "អ.ភ.ឧ." ពីលើ (រូបភាពទី១៨ ឧបសម្ព័ន្ធទី៣)។

**២- ថ្នាក់អគ្គាធិការរង**

សក្តិស្មាមានផ្ទៃកម្ពីពណ៌ខៀវចាស់ ព័ទ្ធជុំវិញដោយក្បាច់ភ្ញីទេសអមដោយខ្សែវេញពណ៌មាសពីរសរសៃ។ នៅផ្នែកខាងលើមានឡេវរូបព្រះសង្ហារពណ៌មាសមួយនៅជិតកំពូលមុំ។ នៅចំកណ្តាលមានប៉ាក់រូបសញ្ញាសម្គាល់មន្ត្រីនគរបាលយុត្តិធម៌នៃក្រសួងទេសចរណ៍ពណ៌មាស។ ផ្នែកខាងក្រោមមានខ្សែវេញពណ៌មាសបួនខ្សែនិងមានក្បាច់ផ្កាចន្ទន៍និងក្បាច់ភ្ញីទេសពណ៌មាស ព្រមទាំងមានប៉ាក់អក្សរកាត់ "អ.ភ.ឧ." ពីលើ (រូបភាពទី១៨ ឧបសម្ព័ន្ធទី៣)។

**៣- ថ្នាក់អធិការ**

សក្តិស្មាមានផ្ទៃកម្ពីពណ៌ខៀវចាស់ ព័ទ្ធជុំវិញដោយក្បាច់ភ្ញីទេសអមដោយខ្សែវេញពណ៌មាសពីរសរសៃ។ នៅផ្នែកខាងលើមានឡេវរូបព្រះសង្ហារពណ៌មាសមួយនៅជិតកំពូលមុំ។ នៅចំកណ្តាលមានប៉ាក់រូបសញ្ញាសម្គាល់មន្ត្រីនគរបាលយុត្តិធម៌នៃក្រសួងទេសចរណ៍ពណ៌មាស។ ផ្នែកខាងក្រោមមានខ្សែវេញពណ៌មាសបីខ្សែ និងមានក្បាច់ផ្កាចន្ទន៍ និងក្បាច់ភ្ញីទេសពណ៌មាស ព្រមទាំងមានប៉ាក់អក្សរកាត់ "អ.ភ.ឧ." ពីលើ (រូបភាពទី១៨ ឧបសម្ព័ន្ធទី៣)។

**៤- ថ្នាក់ប្រធានមន្ទីរទេសចរណ៍រាជធានី ខេត្ត**

សក្តិស្មាមានផ្ទៃកម្ពីពណ៌ខៀវចាស់ ព័ទ្ធជុំវិញដោយក្បាច់ភ្ញីទេសអមដោយខ្សែវេញពណ៌មាសពីរសរសៃ។ នៅផ្នែកខាងលើមានឡេវរូបព្រះសង្ហារពណ៌មាសមួយនៅជិតកំពូលមុំ។ នៅចំកណ្តាលមានប៉ាក់រូបសញ្ញាសម្គាល់មន្ត្រីនគរបាលយុត្តិធម៌នៃក្រសួងទេសចរណ៍ពណ៌មាស។ ផ្នែកខាងក្រោមមានខ្សែវេញពណ៌មាសពីរខ្សែ និងមានក្បាច់ផ្កាចន្ទន៍ និងក្បាច់ភ្ញីទេសពណ៌មាស ព្រមទាំងមានប៉ាក់អក្សរកាត់ "អ.ភ.ឧ." ពីលើ (រូបភាពទី១៨ ឧបសម្ព័ន្ធទី៣)។

**៥- ថ្នាក់ប្រធានការិយាល័យថ្នាក់កណ្តាលនិងអនុប្រធានមន្ទីរទេសចរណ៍រាជធានី ខេត្ត**

សក្តិស្មាមានផ្ទៃកម្ពីពណ៌ខៀវចាស់ ព័ទ្ធជុំវិញដោយក្បាច់ភ្ញីទេសអមដោយខ្សែវេញពណ៌មាសពីរសរសៃ។ នៅផ្នែកខាងលើមានឡេវរូបព្រះសង្ហារពណ៌មាសមួយនៅជិតកំពូលមុំ។ នៅចំកណ្តាលមានប៉ាក់រូបសញ្ញាសម្គាល់មន្ត្រីនគរបាលយុត្តិធម៌នៃក្រសួងទេសចរណ៍ពណ៌មាស។ ផ្នែកខាងក្រោមមានខ្សែវេញពណ៌មាសមួយខ្សែនិងមានក្បាច់ផ្កាចន្ទន៍និងក្បាច់ភ្ញីទេសពណ៌មាស ព្រមទាំងមានប៉ាក់អក្សរកាត់ "អ.ភ.ឧ." ពីលើ (រូបភាពទី១៨ ឧបសម្ព័ន្ធទី៣)។/.../



www.pheakdeylaw.com

**៦- ថ្នាក់អនុប្រធានការិយាល័យថ្នាក់កណ្តាលនិងប្រធានការិយាល័យមន្ទីរទេសចរណ៍រាជធានី ខេត្ត**

សក្តិស្មាមានផ្ទៃកម្ពីពណ៌ខៀវចាស់ ព័ទ្ធជុំវិញដោយក្បាច់ភ្ញីទេសអមដោយខ្សែវេញពណ៌ទឹកប្រាក់ពីរសរសៃ។ នៅផ្នែកខាងលើមានឡេវរូបព្រះសង្ការពណ៌ទឹកប្រាក់មួយនៅជិតកំពូលមុំ។ នៅចំកណ្តាលមានប៉ាក់រូបសញ្ញាសម្គាល់មន្រ្តីនគរបាលយុត្តិធម៌នៃក្រសួងទេសចរណ៍ពណ៌ទឹកប្រាក់។ ផ្នែកខាងក្រោមមានខ្សែវេញពណ៌ទឹកប្រាក់មួយខ្សែនិងមានក្បាច់ផ្កាចន្ទន៍និងក្បាច់ភ្ញីទេសពណ៌ទឹកប្រាក់ ព្រមទាំងមានប៉ាក់អក្សរកាត់ "អ.ភ.ឧ." ពីលើ(រូបភាពទី១៨ ឧបសម្ព័ន្ធទី៣)។

**៧- ថ្នាក់មន្ត្រីនិងអនុប្រធានការិយាល័យមន្ទីរទេសចរណ៍រាជធានី ខេត្ត ទទួលបន្ទុកអធិការកិច្ច**

សក្តិស្មាមានផ្ទៃកម្ពីពណ៌ខៀវចាស់ ព័ទ្ធជុំវិញដោយក្បាច់ភ្ញីទេសអមដោយខ្សែវេញពណ៌ទឹកប្រាក់ពីរសរសៃ។ នៅផ្នែកខាងលើមានឡេវរូបព្រះសង្ការពណ៌ទឹកប្រាក់មួយនៅជិតកំពូលមុំ។ នៅចំកណ្តាលមានប៉ាក់រូបសញ្ញាសម្គាល់មន្រ្តីនគរបាលយុត្តិធម៌នៃក្រសួងទេសចរណ៍ពណ៌ទឹកប្រាក់។ ផ្នែកខាងក្រោមមានក្បាច់ផ្កាចន្ទន៍និងក្បាច់ភ្ញីទេសពណ៌ទឹកប្រាក់ ព្រមទាំងមានប៉ាក់អក្សរកាត់ "អ.ភ.ឧ." ពីលើ(រូបភាពទី១៨ ឧបសម្ព័ន្ធទី៣)។

## ជំពូកទី៥
## ការប្រើប្រាស់ឯកសណ្ឋាន សញ្ញាសម្គាល់ និងសញ្ញាសក្តិ

**មាត្រា៥ .-**

ឯកសណ្ឋាន សញ្ញាសម្គាល់ និងសញ្ញាសក្តិ ត្រូវបានប្រើប្រាស់ដោយមន្រ្តីអធិការកិច្ចទេសចរណ៍ដើម្បី៖

១- បំពេញការងារប្រចាំថ្ងៃក្នុងអង្គភាព។

២- បំពេញបេសកកម្មពង្រឹងការអនុវត្តច្បាប់ស្តីពីទេសចរណ៍និងច្បាប់នានាពាក់ព័ន្ធក្នុងប្រតិបត្តិការស្រាវជ្រាវ តាមដាន ស៊ើបអង្កេត ត្រួតពិនិត្យ ទប់ស្កាត់ និងបង្ក្រាបបទល្មើសក្នុងវិស័យទេសចរណ៍។

៣- ចូលរួមក្នុងពិធីបុណ្យជាតិ ប្រជុំ និង/ឬសន្និសីទផ្លូវការផ្សេងៗទៀត។

៤- ចូលរួមក្នុងសវនាការនៅតុលាការ។

**មាត្រា៦ .-**

មន្រ្តីអធិការកិច្ចទេសចរណ៍ម្នាក់ៗត្រូវទទួលបានឯកសណ្ឋាន សញ្ញាសម្គាល់ និងសញ្ញាសក្តិ ដូចមានចែងក្នុងអនុក្រឹត្យនេះ ចំនួន២(ពីរ)សម្រាប់ ដើម្បីប្រើប្រាស់ក្នុងរយៈពេល១(មួយ)ឆ្នាំ តាមទំហំនៃថវិកាជាតិប្រចាំឆ្នាំដែលបានវិភាជជូន។

## ជំពូកទី៦
## ទោសប្បញ្ញត្តិ

**មាត្រា៧ .-**

ជនណាក្លែងបន្លំស្លៀកពាក់ឯកសណ្ឋាន សញ្ញាសម្គាល់ និងសញ្ញាសក្តិរបស់មន្រ្តីអធិការកិច្ចទេសចរណ៍ ដូចមានកំណត់ក្នុងអនុក្រឹត្យនេះ ត្រូវផ្តន្ទាទោសតាមច្បាប់ជាធរមាន។



www.pheakdeylaw.com

## ជំពូកទី៧
## អន្តរប្បញ្ញត្តិ

**មាត្រា៨ .-**

ឯកសណ្ឋាន សញ្ញាសម្គាល់ និងសញ្ញាសក្តិរបស់មន្ត្រីអធិការកិច្ចទេសចរណ៍ ដែលកំពុងប្រើប្រាស់បច្ចុប្បន្ន ត្រូវបន្តរហូតមានឯកសណ្ឋាន សញ្ញាសម្គាល់ និងសញ្ញាសក្តិរបស់មន្ត្រីអធិការកិច្ចទេសចរណ៍ថ្មីមកជំនួស។

## ជំពូកទី៨
## អវសានប្បញ្ញត្តិ

**មាត្រា៩ .-**

អនុក្រឹត្យលេខ១៩៩ អនក្រ.បក ចុះថ្ងៃទី២៦ ខែកញ្ញា ឆ្នាំ២០១៦ ស្តីពីឯកសណ្ឋាន សញ្ញាសម្គាល់ និងសញ្ញាសក្តិរបស់មន្ត្រីអធិការកិច្ចទេសចរណ៍ និងបទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា១០ .-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងទេសចរណ៍ រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃព្រហស្បតិ៍ ៣ កើត ខែ[illegible] ឆ្នាំ[illegible] សំរិទ្ធិស័ក ព.ស.២៥៦២

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ[illegible]ភា ឆ្នាំ២០១៨

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីគោរពជម្រាបជូន
សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី សូមហត្ថលេខា

**រដ្ឋមន្ត្រីក្រសួងទេសចរណ៍**

**ថោង ខុន**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា១០
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ



www.pheakdeylaw.com

## រូបភាពទី១ ឧបសម្ព័ន្ធទី១

**នៃអនុក្រឹត្យលេខ...៦៤...អនក្រ.បក.ចុះថ្ងៃទី.....១៧.....ខែ...ឧសភា...ឆ្នាំ២០១៨**

**ស្តីពីឯកសណ្ឋាន សញ្ញាសម្គាល់ និងសញ្ញាសក្តិរបស់មន្ត្រីអធិការកិច្ចទេសចរណ៍**

**អាវធំទារីដៃវែងបុរសស្ត្រី**



**មើលពីខាងមុខ** **មើលពីខាងក្រោយ**

www.pheakdeylaw.com

## រូបភាពទី២ ឧបសម្ព័ន្ធទី១

**នៃអនុក្រឹត្យលេខ..៦៤..អនក្រ.បក ចុះថ្ងៃទី..១៧.....ខែ.ឧសភា...ឆ្នាំ២០១៨**

**ស្តីពីឯកសណ្ឋាន សញ្ញាសម្គាល់ និងសញ្ញាសក្តិរបស់មន្ត្រីអធិការកិច្ចទេសចរណ៍**

**អាវធំអាវ៉ីដៃវែងបុរសស្ត្រី**



**មើលពីខាងមុខ**



**មើលពីខាងក្រោយ**

## រូបភាពទី៣ ឧបសម្ព័ន្ធទី១

**នៃអនុក្រឹត្យលេខ..៦៤..អនក្រ.បក..ចុះថ្ងៃទី..១៧.....ខែ..ឧសភា...ឆ្នាំ២០១៨**

**ស្តីពីឯកសណ្ឋាន សញ្ញាសម្គាល់ និងសញ្ញាសក្តិរបស់មន្ត្រីអធិការកិច្ចទេសចរណ៍**

**អាវសាហារីយ៉ែនដៃខ្លីបុរសស្ត្រី**



**មើលពីខាងមុខ**



**មើលពីខាងក្រោយ**

# រូបភាពទី៤ ឧបសម្ព័ន្ធទី១

## នៃអនុក្រឹត្យលេខ..៦៤..អនក្រ.បក ចុះថ្ងៃទី..២៧.....ខែ..ឧសភា...ឆ្នាំ២០១៨

## ស្តីពីឯកសណ្ឋាន សញ្ញាសម្គាល់ និងសញ្ញាសក្តិរបស់មន្ត្រីអធិការកិច្ចទេសចរណ៍

## អាវសាហារីយែនដៃខ្លីបុរសស្ត្រី



មើលពីខាងមុខ មើលពីខាងក្រោយ

www.pheakdeylaw.com

## រូបភាពទី៥ ឧបសម្ព័ន្ធទី១

នៃអនុក្រឹត្យលេខ..៦៤..អនក្រ.បក ចុះថ្ងៃទី..១៧.....ខែ..មករា....ឆ្នាំ២០១៨

**ស្តីពីឯកសណ្ឋាន សញ្ញាសម្គាល់ និងសញ្ញាសក្តិរបស់មន្ត្រីអធិការកិច្ចទេសចរណ៍**

**អាវសឺមីដៃវែងពាក់ក្នុងអាវធំបុរសស្ត្រី**



**មើលពីខាងមុខ**

## រូបភាពទី៦ ឧបសម្ព័ន្ធទី១

**នៃអនុក្រឹត្យលេខ.៦៤.អនក្រ.បក. ចុះថ្ងៃទី..១៧.....ខែ.ឧសភា...ឆ្នាំ២០១៨**

**ស្តីពីឯកសណ្ឋាន សញ្ញាសម្គាល់ និងសញ្ញាសក្តិរបស់មន្ត្រីអធិការកិច្ចទេសចរណ៍**

**ខោជើងវែងបុរស**



**មើលពីខាងមុខ** **មើលពីខាងក្រោយ**

www.pheakdeylaw.com

## រូបភាពទី៧ ឧបសម្ព័ន្ធទី១

នៃអនុក្រឹត្យលេខ...៦៤...អនក្រ.បក.ចុះថ្ងៃទី...១៧.....ខែ...ឧសភា...ឆ្នាំ២០១៨

## ស្តីពីឯកសណ្ឋាន សញ្ញាសម្គាល់ និងសញ្ញាសក្តិរបស់មន្ត្រីអធិការកិច្ចទេសចរណ៍

ក្រវាត់កបុរសស្ត្រី



www.pheakdeylaw.com

## រូបភាពទី៨ ឧបសម្ព័ន្ធទី១

នៃអនុក្រឹត្យលេខ.៦៤..អនក្រ.បក.ចុះថ្ងៃទី...១៧....ខែ..ឧសភា..ឆ្នាំ២០១៨

ស្តីពីឯកសណ្ឋាន សញ្ញាសម្គាល់ និងសញ្ញាសក្តិរបស់មន្ត្រីអធិការកិច្ចទេសចរណ៍

ស្បែកជើង ស្រោមជើងបុរស





www.pheakdeylaw.com

# រូបភាពទី៩ ឧបសម្ព័ន្ធទី១

នៃអនុក្រឹត្យលេខ៦៤ អនក្រ.បក ចុះថ្ងៃទី...១៧.....ខែ...ឧសភា....ឆ្នាំ២០១៨

ស្តីពីឯកសណ្ឋាន សញ្ញាសម្គាល់ និងសញ្ញាសក្តិរបស់មន្ត្រីអធិការកិច្ចទេសចរណ៍

ខ្សែក្រវាត់



www.pheakdeylaw.com

## រូបភាពទី១០ ឧបសម្ព័ន្ធទី១

នៃអនុក្រឹត្យលេខ.៦៤..អនក្រ.បក.ចុះថ្ងៃទី...១៧.....ខែ..ឧសភា....ឆ្នាំ២០១៨

ស្តីពីឯកសណ្ឋាន សញ្ញាសម្គាល់ និងសញ្ញាសក្តិរបស់មន្ត្រីអធិការកិច្ចទេសចរណ៍

មួកកាស្កេតបុរស



សម្រាប់ថ្នាក់អគ្គាធិការ



សម្រាប់ថ្នាក់អគ្គាធិការរង



សម្រាប់ថ្នាក់អធិការ



សម្រាប់ថ្នាក់ប្រធានមន្ទីររាជធានី ខេត្ត



សម្រាប់ថ្នាក់ប្រធានការិ. និងអនុប្រធានមន្ទីររាជធានី ខេត្ត



សម្រាប់ថ្នាក់អនុប្រធានការិ. និងប្រធានការិ.មន្ទីររាជធានី ខេត្ត



សម្រាប់ថ្នាក់មន្ត្រីអធិការកិច្ច និងអនុប្រធានការិ.មន្ទីររាជធានី ខេត្ត

www.pheakdeylaw.com

# រូបភាពទី១១ ឧបសម្ព័ន្ធទី១

នៃអនុក្រឹត្យលេខ.៦៤.អនក្រ.បក.ចុះថ្ងៃទី..១៧......ខែ..ឧសភា...ឆ្នាំ២០១៨

ស្តីពីឯកសណ្ឋាន សញ្ញាសម្គាល់ និងសញ្ញាសក្តិរបស់មន្ត្រីអធិការកិច្ចទេសចរណ៍

សំពត់ស្ត្រី



មើលពីខាងមុខ មើលពីខាងក្រោយ

www.pheakdeylaw.com

## រូបភាពទី១២ ឧបសម្ព័ន្ធទី១

នៃអនុក្រឹត្យលេខ.៦៤អនក្រ.បក ចុះថ្ងៃទី..១៧.....ខែ..ឧសភា...ឆ្នាំ២០១៨

ស្តីពីឯកសណ្ឋាន សញ្ញាសម្គាល់ និងសញ្ញាសក្តិរបស់មន្ត្រីអធិការកិច្ចនេសាទឈើ

ស្បែកជើងឃ្លុបស្ត្រី



www.pheakdeylaw.com

# រូបភាពទី១៣ ឧបសម្ព័ន្ធទី១

នៃអនុក្រឹត្យលេខ៦៤..អនក្រ..បក..ចុះថ្ងៃទី...១៧....ខែ..ឧសភា...ឆ្នាំ២០១៨

ស្តីពីឯកសណ្ឋាន សញ្ញាសម្គាល់ និងសញ្ញាសក្តិរបស់មន្ត្រីអធិការកិច្ចទេសចរណ៍

មួកស្ត្រី



សម្រាប់ថ្នាក់អគ្គាធិការ



សម្រាប់ថ្នាក់អគ្គាធិការរង



សម្រាប់ថ្នាក់អធិការ



សម្រាប់ថ្នាក់ប្រធានមន្ទីររាជធានី ខេត្ត



សម្រាប់ថ្នាក់ប្រធានការិ. និងអនុប្រធានមន្ទីររាជធានី ខេត្ត



សម្រាប់ថ្នាក់អនុប្រធានការិ. និងប្រធានការិ.មន្ទីររាជធានី ខេត្ត



សម្រាប់ថ្នាក់មន្ត្រីអធិការកិច្ច និងអនុប្រធានការិ.មន្ទីររាជធានី ខេត្ត

www.pheakdeylaw.com

## រូបភាពទី១៤ ឧបសម្ព័ន្ធទី២

នៃអនុក្រឹត្យលេខ៦៤អនក្រ.បក ចុះថ្ងៃទី...១៧...ខែ...ឧសភា...ឆ្នាំ២០១៨

ស្តីពីឯកសណ្ឋាន សញ្ញាសម្គាល់ និងសញ្ញាសក្តិរបស់មន្ត្រីអធិការកិច្ចទេសចរណ៍

ស្លាកសញ្ញាក្រសួងទេសចរណ៍




www.pheakdeylaw.com

## រូបភាពទី១៥ ឧបសម្ព័ន្ធទី២

នៃអនុក្រឹត្យលេខ៦៤អនក្រ.បក ចុះថ្ងៃទី....១៧....ខែ...ឧសភា...ឆ្នាំ២០១៨

ស្តីពីឯកសណ្ឋាន សញ្ញាសម្គាល់ និងសញ្ញាសក្តិរបស់មន្ត្រីអធិការកិច្ចទេសចរណ៍

ស្លាកសញ្ញានគរបាលយុត្តិធម៌



www.pheakdeylaw.com

# រូបភាពទី១៦ ឧបសម្ព័ន្ធទី២

## នៃអនុក្រឹត្យលេខ៦៤ អនក្រ.បក. ចុះថ្ងៃទី...១៧....ខែ...ឧសភា....ឆ្នាំ២០១៨

## ស្តីពីឯកសណ្ឋាន សញ្ញាសម្គាល់ និងសញ្ញាសក្តិរបស់មន្ត្រីអធិការកិច្ចទេសចរណ៍

## ស្លាកសញ្ញាសម្គាល់ឈ្មោះ



## រូបភាពទី១៧ ឧបសម្ព័ន្ធទី២

នៃអនុក្រឹត្យលេខ២៤អនក្រ.បកចុះថ្ងៃទី...១៧......ខែ..មករា...ឆ្នាំ២០១៨

ស្តីពីឯកសណ្ឋាន សញ្ញាសម្គាល់ និងសញ្ញាសក្តិរបស់មន្ត្រីអធិការកិច្ចទេសចរណ៍

ស្លាកសញ្ញាសម្គាល់ នៅចុងករអាវឆ្វេងស្តាំ



# រូបភាពទី១៨ ឧបសម្ព័ន្ធទី៣

នៃអនុក្រឹត្យលេខ៦៤អនក្រ.បក ចុះថ្ងៃទី...១៧.....ខែ.វិច្ឆិកា....ឆ្នាំ២០១៨

ស្តីពីឯកសណ្ឋាន សញ្ញាសម្គាល់ និងសញ្ញាសក្តិរបស់មន្ត្រីអធិការកិច្ចទេសចរណ៍

## សញ្ញាសក្តិស្មា



សម្រាប់ថ្នាក់អគ្គាធិការ



សម្រាប់ថ្នាក់អគ្គាធិការរង



សម្រាប់ថ្នាក់អធិការ



សម្រាប់ថ្នាក់ប្រធានមន្ទីររាជធានី ខេត្ត



សម្រាប់ថ្នាក់ប្រធានការិ. និងអនុប្រធានមន្ទីររាជធានី ខេត្ត



សម្រាប់ថ្នាក់អនុប្រធានការិ. និងប្រធានការិ.មន្ទីររាជធានី ខេត្ត



សម្រាប់ថ្នាក់មន្ត្រីអធិការកិច្ច និងអនុប្រធានការិ.មន្ទីររាជធានី ខេត្ត